អង្គភាពសវនកម្មផ្ទៃក្នុង

អត្ថបទប្រចាំខែ

លេខ ២៥/២៤ ចេញផ្សាយ ខែមករា ឆ្នាំ២០២៤

# អ្វីទៅជាសវនកម្មហិរញ្ញវត្ថុ?

ដើម្បីឱ្យអង្គភាពមួយអាចដំណើរការបានជោគជ័យរយៈពេលវែង អង្គភាពនោះចាំបាច់ត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយដ៏រឹងមាំ ក្នុងនោះការគ្រប់គ្រងហិរញ្ញវត្ថុជាផ្នែកមួយដ៏សំខាន់ដែលអង្គភាពត្រូវយកចិត្តទុកដាក់ក្នុងការតាមដានត្រួតពិនិត្យ។ ការអនុវត្តសវនកម្មហិរញ្ញវត្ថុជាផ្នែកមួយដ៏សំខាន់ក្នុងការគាំទ្រដល់ការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

**តើអ្វីទៅជាសវនកម្មហិរញ្ញវត្ថុ?**



តាមការសិក្សាស្រាវជ្រាវលើសៀវភៅណែនាំសវនកម្មផ្ទៃក្នុងដែលដាក់ចេញឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់នូវនិយមន័យសវនកម្មហិរញ្ញវត្ថុថា៖ សវនកម្មហិរញ្ញវត្ថុ ជាប្រភេទនៃសវនកម្មមួយដែលមានតួនាទីក្នុងការពិនិត្យលើគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការពិនិត្យនូវបង្កាន់ដៃទំនិញ និងកិច្ចការទូទាត់ថវិកានៃប្រតិបត្តិការនីមួយៗ។ គោលបំណងនៃការធ្វើសវនកម្មប្រភេទនេះ គឺដើម្បីផ្ទៀងផ្ទាត់ថាមានយន្តការត្រួតពិនិត្យគ្រប់គ្រាន់ចំពោះសាច់ប្រាក់ និងទ្រព្យប្រហាក់ប្រហែលដទៃទៀតដែលត្រូវមានយន្តការគ្រប់គ្រងហ្មត់ចត់លើការទិញ និងការប្រើប្រាស់ធនធានបានត្រឹមត្រូវ។

ជាមួយគ្នានេះដែរតាមរយៈការស្រាវជ្រាវលើស្ថាប័នអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល INTOSAI ( ISSAI 200-Financial Audit Principles) បានចែងថា៖ សវនកម្មហិរញ្ញវត្ថុ គឺជាការកំណត់ដោយផ្អែកលើភស្តុតាងសវនកម្មដែលប្រមូលបានដើម្បីវាយតម្លៃថាតើព័ត៌មានហិរញ្ញវត្ថុរបស់អង្គភាពដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពបានបញ្ចប់ត្រឹមត្រូវ និងបានរៀបចំស្របតាមក្របខ័ណ្ឌបទប្បញ្ញត្តិដែលបានអនុវត្ត។

ការធ្វើសវនកម្មហិរញ្ញវត្ថុ គឺជាគន្លឹះសម្រាប់អង្គភាពក្នុងការបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួន។ ការធ្វើសវនកម្មហិរញ្ញវត្ថុបានទៀងទាត់អាចធ្វើឱ្យអង្គភាពកំណត់បាននូវ

សញ្ញាណនៃបញ្ហាមួយចំនួនដែលអង្គភាពត្រូវរៀបចំ និងដោះស្រាយបានចំគោលដៅ។ លទ្ធផលនៃការធ្វើសវនកម្មហិរញ្ញវត្ថុនឹងកំណត់បានថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមានលក្ខណៈត្រឹមត្រូវ ពេញលេញនិងអនុលោមតាមបទប្បញ្ញត្តិ ដែលវាមានសារៈសំខាន់សម្រាប់អង្គភាពដើម្បីបញ្ចៀសរាល់នូវការអនុវត្តមិនត្រឹមត្រូវ។



យោងតាមការសិក្សាស្រាវជ្រាវតាមរយៈខ្លឹមសារខាងលើបានបង្ហាញឱ្យឃើញថាការអនុវត្តសវនកម្មហិរញ្ញវត្ថុមានសារៈសំខាន់សម្រាប់អង្គភាពរងសវនកម្មដើម្បី លុបបំបាត់នូវរាល់សកម្មភាពកេងបន្លំ ជួយឱ្យអង្គភាពអាចដោះស្រាយបញ្ហាដែលកើតមានបានចំគោលដៅ។ លើសពីនេះការធ្វើសវនកម្មហិរញ្ញវត្ថុជាគោលដៅចម្បងដែលអង្គភាពត្រូវយកចិត្តទុកដាក់ខ្ពស់ និងអនុវត្តសវនកម្មហិរញ្ញវត្ថុជាប្រចាំដើម្បីធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពសន្សំសំចៃក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់អង្គភាព។


**អត្ថបទ÷** លោក **សោភា សុភីស័ក**



**ឯកសារយោង÷** *១. សៀវភៅណែនាំសវនកម្មផ្ទៃក្នុង របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*២. INTOSAI ( ISSAI 200- Financial Audit Principles)*

*៣. IIA (Institute Of Internal Auditor)*



អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website